អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ ក្រោមប្រធានបទ ការបំភ្លឺស្មារតីពុទ្ធសាសនិកជនខ្មែរ អំពីការកើតមានវិបត្តិរបស់ព្រះសង្ឃខ្មែរខ្លះនៅប្រទេសកម្ពុជា ។

www.hoksavann.org

ថ្ងៃទី៣១ ធ្នូ ២០១១



ក្នុងរយៈកាលបីបួនអាទិត្យកន្លងមកនេះ តាមទំព័រសារពត៌មាន ជាពិសេសសារពត៌មានតាមគេហទំព័របានផ្សាយថា ព្រះសង្ឃខ្មែរខ្លះបានត្រូវគំរាមកំហែង ព្រះសង្ឃខ្លះបានត្រូវអាជ្ញាធរខ្មែរកោះហៅទៅសាកសួរ អំពីបញ្ហាពាក់ព័ន្ធនឹងនយោបាយ ព្រះសង្ឃខ្លះបានត្រូវចាប់ផ្សឹកដោយចោទថាលោកខុសវិន័យ ព្រះសង្ឃខ្លះបានត្រូវគេផ្សាយរូបលោកនៅជាមួយស្រ្តីក្នុងបន្ទប់ស្ងាត់ ។

សូមទាញអារម្មណ៍ពុទ្ធសាសនិកជនខ្មែរ គប្បីពិចារណាឲ្យបានជ្រាលជ្រៅចំពោះបញ្ហាទាំងនេះ ។ ការគំរាមកំហែងនយោបាយពិតជាកើតមាន ព្រោះប្រទេសកម្ពុជាសព្វថ្ងៃមានគណបក្សនយោបាយច្រើនគណបក្សនីមួយៗតែងរកមធ្យោបាយគ្រប់បែបយ៉ាងទាញការគាំទ្រឲ្យគណបក្សរបស់ខ្លួន ។គណបក្សប្រឆាំងមានលទ្ធភាពតិចណាស់ ដែលអាចគំរាមកំហែងព្រះសង្ឃនិងពុទ្ធបរិស័ទឲ្យគាំទ្រគណបក្សខ្លួន ក្រៅពីគណបក្សកាន់អំណាច ។គេប្រើវិធីពីរយ៉ាង គឺវិធីទន់ភ្លន់សំដីផ្អែមល្ហែមជាមួយនិងការផ្ដល់សម្ភារៈផង និងវិធីគំរាមកំហែងសំឡុតស្មារតី និងចោទឲ្យមានកំហុសចំពោះព្រះសង្ឃនិងពុទ្ធសាសនិកជនណាដែលគេមើលឃើញថា មិនចូលបក្សគេ ។

ចំពោះការចាប់ផ្សឹកព្រះសង្ឃវិញ អាជ្ញាធរខាងផ្លូវអាណាចក្រមិនត្រូវផ្សឹកព្រះសង្ឃទេ តែនៅលើវិន័យធរសង្ឃវិនិច្ឆ័យសេចក្ដី ដោយផ្អែកទៅលើព្រះវិន័យជាគោលវិនិច្ឆ័យ ។ ជាការប្រមាថមើលងាយព្រះពុទ្ធសាសនាណាស់របស់អាជ្ញាធរដែលផ្សឹកព្រះសង្ឃរំលងគណសង្ឃ ទោះបីលោកមានកំហុសទាក់ទងនឹងផ្លូវអាណាចក្រក៏ដោយ ក៏ត្រូវឲ្យព្រះសង្ឃវិនិច្ឆ័យជាមុន ។ អំពីបញ្ហាចោទថាលោកមានកំហុសរហូតចាក់ផ្សឹកនេះ ក៏គួរពិចារណាឲ្យបានល្អិតល្អន់ ជួនកាលដោយកំហុសលោកផ្ទាល់ពិតមែន ព្រោះនេះជារឿងធម្មតាចំពោះព្រះសង្ឃនៅបុថុជ្ជនអាចមានកំហុស សូម្បីសម័យពុទ្ធកាលក៏មានព្រះសង្ឃប្រព្រឹត្តខុស ដូច្នេះហើយបានជាព្រះពុទ្ធបញ្ញត្តិវិន័យ ដើម្បីឲ្យព្រះសង្ឃដែលមានបកំហុសស្រាលៗ ធ្វើកិច្ចតាមព្រះវិន័យឲ្យបរិសុទ្ធឡើងវិញ ចំណែកព្រះភិក្ខុសង្ឃដែលមានកំហុសធ្ងន់ ត្រូវផ្លាស់ភេទទៅជាគ្រហស្ថវិញ ។ ផ្ទុយមកវិញ ព្រះភិក្ខុសង្ឃខ្លះពុំមានកំហុសទេ តែត្រូវគេចោទឲ្យមានកំហុស ដោយប្រឌិតភស្តុតាងផ្សេងៗ ដោយការចង់ឈ្នះចាញ់គ្នា និងដោយផ្លូវនយោបាយ ។ ប្រទេសកម្ពុជាសព្វថ្ងៃនេះ យុត្តិធម៌កំរកើតមានណាស់ ព្រោះតុលាការពុករលួយនៅក្រោមអ្នកមានអំណាច និងនៅក្រោមអ្នកមានដុល្លារច្រើន ។ ដូច្នេះហើយបានជាគេយកតុលាការបែបនេះ ជាឧបករណ៍សំរាប់កំចាត់អ្នកណាដែលគេត្រូវកំចាត់មានប្រសិទ្ធិភាពណាស់ ។ យ៉ាងណាមិញ ចំពោះព្រះសង្ឃណាដែលមានឥទ្ធិពលពុំស្ដាប់បង្គាប់គេ ក៏គេលៃលកចាត់ការបែបណាមួយដើម្បីឲ្យវិនាសដូចគ្នាដែរ ។ បញ្ហាមួយទៀត កើតពីសាសនាដទៃមានបំណងបង្ខូចតម្លៃព្រះសង្ឃព្រះពុទ្ធសាសនាដូចជាចូលមកបួសបន្លំ ឬជួលស្រ្តីឲ្យបង្កាច់បង្ខូចព្រះសង្ឃដែលមានចំណេះដឹងខ្ពស់ ដែលពុទ្ធបរិស័ទគោរពរាប់អានច្រើន ។ មធ្យោបាយនេះគេមានប្រើនៅប្រទេសថៃរួចមកហើយ ។ សម័យពុទ្ធកាល ពួកនិគ្រន្ថបានជួលនាងចិញ្ចាឲ្យដេរតិះដៀលព្រះពុទ្ធ ហើយយកឈើមកធ្វើជាកូន មួលបង្កាច់ព្រះពុទ្ធក្នុងផ្លូវកាមគុណ ។ ដូច្នេះផ្លូវអាណាចក្រមានភាពច្របូកច្របល់ណាស់ ដណ្ដើមឈ្នះចាញ់គ្នាដោយលោភៈ ទោសៈ មោហៈ ដូច្នោះហើយបានជាព្រះពុទ្ធជាម្ចាស់បានសំដែងក្នុងកាលាមសូត្រ កុំឲ្យជឿអាការៈ១០យ៉ាង មានមិនឲ្យជឿពាក្យដែលនិយាយតៗគ្នាជាដើម មុននឹងធ្វើត្រូវពិចារណារកការពិតសិន ។ ដូចពត៌មានថា ព្រះសង្ឃត្រូវគេចាប់ផ្សឹកជាដើម តើការចាប់ផ្សឹកនោះជាកំហុសរបស់លោកពិតមែន ឬជាការមួលបង្កាច់ ។ ព្រះសង្ឃដែលនៅរួមជាមួយស្រ្តីក្នុងបន្ទប់តែពីរនាក់ តើជាការពិតឬទេ ឬជាការកាត់ត តាមបច្ចេកទេសវិជ្ជាកាត់ត ក្នុងគោលបំណងបង្កាច់បង្ខូចគ្នាទេ ព្រោះគេអាចយករូបពីរផ្សេងគ្នាមកបញ្ចូលគ្នាដោយគ្មានស្នាមអ្វីឡើយ ហាក់ដូចជារូបថតតែមួយ ។

តាមការវិភាគមកហើយនេះ បើព្រះភិក្ខុសង្ឃអង្គណាដែលមិនបានធ្វើកំហុស តែបានទទួលទោសដោយការមួលបង្កាច់ចាត់ជាអ្នករងគ្រោះទៅវិញ ។ ដូច្នេះបើពុទ្ធបរិស័ទបានទទួលពត៌មានទាំងនេះ មិនគួរផ្ដន្ទាទោសតែត្រូវពិចារណាឲ្យកើតធម្មសង្វេគវិញ ហើយរកមធ្យោបាយដោះស្រាយកុំឲ្យមនុស្សអាក្រក់ចោទព្រះសង្ឃដែលបរិសុទ្ធ នាំឲ្យខូចកិត្តិយសព្រះសង្ឃ ។ នៅភ្នំពេញ ព្រះសង្ឃកម្ពុជាក្រោមមួយអង្គបានត្រូវសុគតដោយអាថ៌កំបាំង អាជ្ញាធរខ្មែរមិនបានរកមុខអ្នកធ្វើគតលោកឡើយ ។ កាលពីជំនាន់ដើម អំណាចមន្រ្តីសង្ឃជាមុខងារឯករាជ្យ ស្ថិតនៅដោយឡែកពីអំណាចផ្លូវអាណាចក្រ តែសព្វថ្ងៃនេះច្របូកច្របល់អំណាចផ្លូវពុទ្ធចក្រហាក់ដូចជានៅក្រោមការត្រួតត្រារបស់ផ្លូវអាណាចក្រ កន្លែងខ្លះបញ្ហាវិន័យដែលព្រះសង្ឃត្រូវដោះស្រាយ តែបែរជាធ្វើតាមបញ្ជាផ្លូវអាណាចក្រទៅវិញ ។ តទៅមុខទៀត ដើម្បីឲ្យព្រះពុទ្ធសាសនារឹងមាំនិងរុងរឿងគប្បីពង្រឹងវិន័យផ្នែកព្រះសង្ឃ ហើយមុននឹងអនុញ្ញាតឲ្យកុលបុត្រណាមួយបួស ត្រូវពិនិត្យមើលឲ្យបានច្បាស់លាស់កុំឲ្យមានបញ្ហាក្នុងសាសនា ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ បើគេធ្វើធម្មយាត្រាទៅកាន់ប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទដូចប្រទេសថៃ ភូមា ស្រីលង្កា គេឃើញថា ព្រះសង្ឃខ្មែរកាន់វិន័យតឹងរ៉ឹងជាងព្រះសង្ឃនៃប្រទេសទាំងនោះ ។ ខ្មែរខ្លះធ្លាប់រិះគន់ព្រះសង្ឃខ្មែរខ្លះ ពេលត្រឡប់ពីធ្វើទស្សនកិច្ច បានជ្រះថ្លានឹងព្រះសង្ឃខ្មែរយ៉ាងរឹងមាំវិញ ។ ទោះបីមានព្រះសង្ឃខ្លះប្រព្រឹត្តខុសវិន័យវិន័យ នោះជារឿងធម្មតាទេ ព្រោះលោកមិនទាន់ជាព្រះអរហន្ត កំពុងព្យាយាមប្រព្រឹត្តល្អ ប៉ុន្តែមានការភ្លាំងភ្លាត់ សូមកុំចាប់អារម្មណ៍ថាជារឿងចម្លែក ត្រូវនាំគ្នារក្សាព្រះពុទ្ធសាសនាឲ្យគង់វង់ ដើម្បីជាមាគ៌ាដឹកនាំខ្មែរឲ្យបានសុខចំរើនក្នុងជីវិតបច្ចុប្បន្ន និងបានសំរេចព្រះនិព្វានការរំលត់ទុក្ខក្នុងអនាគតជាតិ ។